# ការសំភាសន៍របស់អ៊ុំស្រី ជុំ សុខំ

កៈ អ្នកដែរសំភាសន៍គេមាន ជាង ស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ អ៊ុំស្រី ជុំ សុខំ

## <u>ការសង្ខេបប្រវត្តិរបស់ អ៊ុំស្រី ជុំ សុខំ</u>

អ៊ុំស្រី ជុំ សុខំ មានអាយុ63ឆ្នាំ នៅក្នុងឆ្នាំ2018 អ៊ុំស្រី ជុំ សុខំ មានភេទស្រី អ៊ុំស្រី ជុំ សុខំ មានទីលំនៅបច្ចុប្បន្ននៅ ភូមិទួល ឃុំមហាសាង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

កៈ
ចឹងជាដំបូងខ្ញុំអរគុណអ៊ុំដែរបានអោយខ្ញុំពិភាក្សាជាមួយយាយដែរទាក់ទងពីប្រវត្តិរបស់អ៊ុំ ហើយការសំភាសន៍ទាំងអស់នេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗៗអោយពួកគាត់ បានស្គាល់ពីប្រវត្តិរបស់ឪពុកម្ដាយនឹង ប្រវត្តិរបស់ដូនតាអ៊ុំចឹងនៅពេលដែរខ្ញុំបានសំភាសន៍អ៊ុំ ហើយនឹងខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដើម្បីតំកល់ទុកអោយអ៊ុំ ចឹងដោយសារតែវេបសាយដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងសំរាប់អ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ដែរបានពិភាក្សាជាមួយតាទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខៈ អត់អីទេលោកគ្រូ

កៈ បាទអ៊ុំបាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍អ៊ុំខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរខ្ញុំបានសំភាសន៍យាយគឺនៅថ្ងៃទី11ខែ4 ឆ្នាំ2018 ហើយឡើងនៅភូមិទួលណាអ៊ុំ

ខៈ ចា៎!!ភូមិទួល

កៈ ឃុំមហាសាងនឹង?

ខ៖  ឃុំមហាសាង ស្រុកភ្នំស្រួចនឹង ខេត្តកំពង់ស្ពឺ

ក៖  ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ចុះចឹងសំរាប់អ៊ុំមានឈ្មោះពេញនឹងឈ្មោះអីគេដែរអ៊ុំ?

ខ៖  ខ្ញុំមានឈ្មោះជុំ សុខំ

ក៖  ចុះមានឈ្មោះហៅក្រៅទេអ៊ុំ?

ខ៖  អត់មានទេខ្ញុំគេហៅក្រៅនឹងមានឈ្មោះយាយ ខន

ក៖  មានឈ្មោះយាយ ខន ហោសអ៊ុំ
ចុះកាលពីក្មេងនឹងធ្លាប់មាននរណាហៅឈ្មោះអ៊ុំអីផ្សេងដែរទេ?

ខ៖  មានតែឈ្មោះ ជុំ សុខំនឹងរហូតនឹងតាំងពីខ្ញុំកើតមកនឹង

ក៖  ចឹងហោសអ៊ុំ ចុះសព្វថ្ងៃនឹងអ៊ុំអាយុប៉ុន្មានដែរអ៊ុំ?

ខ៖  ខ្ញុំអាយុ63ឆ្នាំ

ក៖  ចឹងអ៊ុំអាយុ63ឆ្នាំ ចុះអ៊ុំមានដឹងថាអ៊ុំកើតនៅថ្ងៃខែឆ្នាំណាដែរទេអ៊ុំ?

ខ៖  ខ្ញុំអត់ដឹងទេទាល់តែមើលនៅក្នុងអត្តសញ្ញាណប័ណ

ក៖  ចឹងទាល់តែមើលនៅក្នុងអត្តសញ្ញាណប័ណណអ៊ុំ
អូខ្ញុំអត់បានយកទូរស័ព្ទមួយទៀតមកទេ ចាំមួយភ្លេតសិនអ៊ុំចឹងអ៊ុំអាយុ63ឆ្នាំណអ៊ុំ?

ខ៖  ចា៎!!នឹងហើយ

ក៖  ចុះអ៊ុំឆ្នាំច័ន្ទគតិអ៊ុំមានឆ្នាំអីគេដែរអ៊ុំលក្ខណៈឆ្នាំជូត ឆ្លូវ ខាល ថោះហាស?

ខ៖  អ៊ូ៎!!ពិបាកដែរនឹងខ្ញុំមិនសូវចេះរាប់ដែរនឹងហាស

ក៖  អត់ទេអាឆ្នាំជូត ឆ្លូវ ខាល ថោះហាស?

ខ៖  អ៊ូ៎!!មមែ វ៉ក វកា ចរ កោ ជូត ឆ្លូវ ខាល ថោះ រោង ម៉្សាញ់ មមី មមែអីចឹងនឹងហោស?

ក៖  បាទមួយអ៊ុំមានឆ្នាំអីគេដែរអ៊ុំ?

ខ៖  ខ្ញុំឆ្នាំមមែ

កៈ ចឹងអ៊ុំឆ្នាំមមែណាអ៊ុំ ចឹងអ៊ុំអាយុ63ឆ្នាំចឹងអ៊ុំកើតនៅឆ្នាំ1955ហាសអ៊ុំ?

ខៈ ចា៎!!នឹងហើយ

កៈ ចឹងសំរាប់អ៊ុំបានកើតនៅណាដែរអ៊ុំ នៅភូមិអី ឃុំអីដែរអ៊ុំ?

ខៈ ខ្ញុំកើតនៅបរបូរណ៍ ខេត្តកំពង់ឆ្នាំង ស្រុកបរិបូរណ៍នឹង

កៈ ចុះភូមិអីគេដែរអ៊ុំ?

ខៈ គេហៅភូមិដំរីកូន

កៈ គេហៅភូមិដំរីកូននឹងហោស ចុះឃុំវិញអ៊ុំ?

ខៈ ចា៎!!ខ្ញុំមិនដឹងថាគេហៅឃុំ អីផងនឹងពីព្រោះខ្ញុំចេញមកយូរដែរហើយ

កៈ ប៉ុន្តែនៅស្រុកបរិបូរណ៍នឹងនៅខេត្តកំពង់ឆ្នាំងនឹង?

ខៈ ចា៎!!ពីព្រោះប៉ារបស់ខ្ញុំនឹងគាត់ធ្វើជាទាហ៊ាន ខ្ញុំបានចេញមកជាមួយគាត់នឹង

កៈ បាទអ៊ុំបាទនឹង ចុះសំរាប់អ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ ខ្ញុំមានម្នាក់ឯងនឹង

កៈ អូ៎!!ចឹងអ៊ុំកូនទោលហោសអ៊ុំ?

ខៈ ចា៎!!នឹងហើយចឹង

កៈ ចុះសំរាប់ឪពុករបស់អ៊ុំនឹងមានឈ្មោះអីគេដែរអ៊ុំ?

ខៈ គាត់មានឈ្មោះឈុន ហឹម

កៈ ចុះសព្វថ្ងៃនឹងគាត់នៅរស់រឺយ៉ាងម៉េចដែរអ៊ុំ?

ខៈ គាត់ស្លាប់ហើយនឹង

កៈ ចុះបើប្រៀបធៀបដល់អាឡូវនឹងគាត់អាយុប៉ុន្មានដែរអ៊ុំមានដឹងទេ?

ខៈ គាត់កើតឆ្នាំមមែ

កៈ គាត់កើតនៅឆ្នាំមមែដែរណាអ៊ុំ?

ខ៖ ចា៎!!នឹងហើយ

ក៖ ចុះគាត់កើតនៅណាដែរអ៊ុំមានដឹងទេ?

ខ៖ គាត់កើតនៅឯស្រុកនឹងនៅឯបរិបូរណ៍នឹង

ក៖ នៅឯបរិបូរណ៍នឹងហោសអ៊ុំ ចុះម្ដាយរបស់អ៊ុំនឹងគាត់មានឈ្មោះអីគេដែរទៅអ៊ុំ?

ខ៖ កាត់មានឈ្មោះព្រំ ខន

ក៖ ប៉ុន្តែគាត់នៅរស់រឺយ៉ាងម៉េចដែរអ៊ុំ?

ខ៖ គាត់ស្លាប់បាត់ហើយនឹង

ក៖ អូ៎!!គាត់ស្លាប់ហើយ ចុះគាត់កើតនៅណាដែរអ៊ុំ?

ខ៖ គាត់កើតនៅនឹងទាំងអស់គ្នានឹង

ក៖ ចុះអ៊ុំមានចងចាំថាកាលពីឪពុករបស់អ៊ុំនៅរស់ហាស
កាលពីគាត់យកបានម្ដាយរបស់អ៊ុំហាស
ថាគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមក្រុមគ្រួសារនឹងចិញ្ចឹមជីវិតដែរអ៊ុំ?

ខ៖ គាត់ធ្វើជាទាហ៊ាន

ក៖ គាត់ធ្វើតែទាហ៊ានទេហោសអ៊ុំ?

ខ៖ ចា៎!!គាត់ធ្វើជាទាហ៊ាននឹង

ក៖ ចុះគាត់អត់ដែរធ្វើស្រែដែរទេហោសអ៊ុំ?

ខ៖ គាត់ធ្វើស្រែដែរដល់ខែធ្វើស្រែនឹងគាត់ទៅធ្វើស្រែនឹង
ដល់ពេលដែរធ្វើទាហ៊ាននឹងគាត់មកធ្វើជាទាហ៊ាននឹង

ក៖ អូ៎!!បាទចឹងហោសអ៊ុំ?

ខ៖ ខ្ញុំធ្វើស្រែម្ដាយរបស់ខ្ញុំនឹងធ្វើស្រែ ឪពុករបស់ខ្ញុំនឹងធ្វើជាទាហ៊ាននឹង

ក៖ អូ៎!!បាទអ៊ុំគាត់កាចរឺមួយក៏ស្លូតដែរអ៊ុំ ឪពុករបស់អ៊ុំហាស?

ខ៖ ឪពុករបស់ខ្ញុំនឹងអត់អីទេគាត់ស្លូតទេនឹង

កៈ អូ៎!!ចឹងហោសអ៊ុំ?

ខៈ គាត់ស្លូតទាំងអស់គ្នានឹងហាស

កៈ ចុះម្ដាយរបស់អ៊ុំនឹងស្លូតដែរ?

ខៈ គាត់ស្លូតដែរ

កៈ ចុះគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខៈ ម្ដាយរបស់ខ្ញុំនឹងធ្វើស្រែរកបន្លែបន្លុក ទៅគោះអង្រ្កង់នឹងយកទៅលក់ចឹងទៅឮ

កៈ អូ៎!!បាទអ៊ុំ ចុះអ៊ុំធ្លាប់មានអនុស្សាវរីយ៍អីកាលពីអ៊ុំនៅជាមួយឪពុកម្ដាយរបស់អ៊ុំ ថាធ្លាប់មានអនុស្សាវរីយ៍អីចឹងហាស?

ខៈ អនុស្សាវរីយ៍អីនឹងអត់អត់ចង់ស្លាប់ហើយនឹងដើរទៅរកនឹងហាស

កៈ បាទលក្ខណៈថាទៅធ្វើស្រែធ្វើអីចឹងហោសអ៊ុំ?

ខៈ ចា៎!!ទៅធ្វើស្រែធ្វើភ្លឺនឹងហាស

កៈ បាទអ៊ុំ ចុះឪពុករបស់អ៊ុំនឹងគាត់មានដែរប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅអ៊ុំដែរទេ?

ខៈ គាត់អត់ដែរប្រាប់ផងនឹងហាស

កៈ អូ៎!!ថានៅពីក្មេងនឹងគាត់ធ្វើអីគេនឹងគាត់មិនដែរនិយាយទេណា?

ខៈ គាត់អត់ដែរនិយាយប្រាប់ផងនឹងហាស

កៈ បាទចុះម្ដាយរបស់អ៊ុំវិញនឹង?

ខៈ អត់ដែរនឹង

កៈ ចឹងគាត់អត់ដែរនិយាយអីទេហោសអ៊ុំ?

ខៈ ចា៎!!នឹងហើយ

កៈ ចុះយាយតាខាងឪពុកនឹងអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ ខ្ញុំស្គាល់ដែរនឹង

កៈ ចុះគាត់មានឈ្មោះអីគេដែរទៅ?

ខៈ គាត់មានឈ្មោះតាជុំ នឹងយាយសាយ

កៈ ចុះកាត់កើតនៅណាដែរអ៊ុំមានដឹងទេ?

ខៈ គាត់កើតនៅស្រុកគាត់នឹងនៅស្រុកបរិបូរណ៍

កៈ អូ៎!!យាយតា?

ខៈ ស្រុកគាត់នៅនឹង

កៈ ចុះយាយតាខាងម្ដាយនឹងអ៊ុំមានស្គាល់ឈ្មោះពួកគាត់ដែរទេ?

ខៈ ខ្ញុំអត់ចងចាំដែរនឹងបើម៉ែរបស់ខ្ញុំនឹងកំព្រាដែរនឹង

កៈ អូ៎!!ចុះគាត់កើតនៅណាដែរអ៊ុំមានដឹងទេ?

ខៈ ខ្ញុំអត់ដឹងដែរនឹង

កៈ បាទចុះសំរាប់អ៊ុំមករស់នៅខេត្តនឹងយូរនៅ មករស់នៅនឹងយូរនឹង?

ខៈ ខ្ញុំមករស់នៅនឹងខេត្តនឹងតាំងពីកូនរបស់ខ្ញុំនឹងមួយខួប

កៈ បាទចុះឥឡូវនឹងបងប្រុសអាយុ?

ខៈ ចា៎!!តាំងពីកូនរបស់ខ្ញុំអាបងនឹងខ្ញុំមករស់នៅឆ្នាំ1979

កៈ ប៉ុន្តែបងប្រុសអាយុ28ឆ្នាំ?

ខៈ ចា៎!!នេះកូនពៅគេអាយុ28ឆ្នាំខ្ញុំនៅមានបង2នាក់ទៀតនឹង

កៈ អូ៎!!ចុះបងគេអាយុ?

ខៈ បងគេនឹងអាយុ30ឆ្នាំជាងហើយនឹង

កៈ អូ៎!!គាត់អាយុ30ឆ្នាំជាងហើយណាអ៊ុំ?

ខៈ ចា៎!!នឹងហើយពៅគេនឹងអាយុ28ឆ្នាំហើយនឹង

កៈ ប៉ុន្តែចង់និយាយថាអ៊ុំមកនៅនឹងតាំងពីបងប្រុសនឹងអាយុមួយខួបមែនទេអ៊ុំ?

ខ៖ ចាំ!!បងគេនឹងនៅឯស្រុកត្បូងណោះ នៅភ្នំជាលណោះ

ក៖ អូ៎!!បាទអ៊ុំបាទ?

ខ៖ ហើយវាកើតនៅនឹង ហើយបានប្ដីរបស់ខ្ញុំនឹងបានយកខ្ញុំនៅនឹងវិញនឹង

ក៖ អូ៎!!បាទអ៊ុំបាទ?

ខ៖ ខ្ញុំទើបតែកើតបានមួយខួបទៅពីរខួបនឹងទេបានខ្ញុំមករស់នៅនឹង

ក៖ បាទយល់អ៊ុំយល់នឹង?

ខ៖ ចាំ!!នឹងចឹង

ក៖ ចុះអ៊ុំគិតថាមានបងប្អូនកូនចៅ
រឺកូនក្មួយណាដែរទៅរស់នៅក្រៅប្រទេសហាសមានទេ?

ខ៖ ចាំ!!អត់មានទេ

ក៖ ទៅធ្វើការងារនៅថៃនឹងនៅវៀតណាមអីក៏អត់មានដែរ?

ខ៖ អត់ៗៗអត់មានទេ

ក៖ ចឹងមានតែធ្វើការងារនៅខ្មែរនឹងទាំងអស់គ្នា?

ខ៖ ចាំ!!ទាំងអស់នឹងហាស

ក៖ អូ៎!!បាទ ចុះសំរាប់អ៊ុំគិតថាស្វាមីរបស់អ៊ុំនឹងមានឈ្មោះអីគេដែរទៅអ៊ុំ?

ខ៖ គាត់មានឈ្មោះរស់ហ្វូ

ក៖ ប៉ុន្តែដូចជា?

ខ៖ ប៉ុន្តែប្ដីរបស់ខ្ញុំមុននឹងគាត់ស្លាប់បាត់ហើយនឹងនៅតែប្ដីក្រោយនឹងទេ

ក៖ អូ៎!!ចឹងហោសអ៊ុំណា?

ខ៖ ចាំ!!វាចឹងនឹង

ក៖ ប្ដីក្រោយនឹងមានឈ្មោះអីគេដែរទៅអ៊ុំ?

ខ៖  ប្ដីខ្ញុំមុននឹងធ្វើជាទាហ៊ាននឹងប្ដីក្រោយនឹងអត់មានធ្វើជាទាហ៊ានទេ

ក៖  ប៉ុន្តែឥឡូវនឹងគាត់នៅជាមួយអ៊ុំដែរទេ?

ខ៖  អត់មាននៅទេគាត់លែងតាំងពីកូនរបស់ខ្ញុំនឹងនៅមួយខួបហោស

ក៖  អូ៎!!អ៊ុំមានចងចាំថាអ៊ុំបានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃខែឆ្នាំណាដែរទេ?

ខ៖  ខ្ញុំហោសនៅប្ដីក្រោយហោស

ក៖  បាទអ៊ុំបាទ?

ខ៖  នៅក្នុងឆ្នាំ1979នឹង

ក៖  នៅក្នុងឆ្នាំ1979ណាអ៊ុំ?

ខ៖  ចា៎!!នៅក្នុងឆ្នាំ1979នឹង1980នឹង

ក៖  អូ៎!!ឪពុកម្ដាយជាអ្នករៀបចំអោយយើងណាអ៊ុំ?

ខ៖  អត់មានទេ

ក៖  រៀបចំដោយខ្លួនឯង?

ខ៖  រៀបដោយចិត្តខ្លួនឯងនឹងហាស

ក៖  អូ៎!!ចឹងហោសអ៊ុំ?

ខ៖  ចុះគ្មានម្ដាយឪពុកផងនឹង

ក៖  ចុះសំរាប់អ៊ុំគិតថា អ៊ុំមានធ្លាប់បានរៀនភាសាខ្មែរដែរទេអ៊ុំ?

ខ៖  ខ្ញុំរៀនតែខ្មែរនឹង

ក៖  អ៊ុំបានរៀនបានថ្នាក់ទីប៉ុន្មានដែរទៅ?

ខ៖  ខ្ញុំហោសខ្ញុំភ្លេចអស់ហើយនឹងខ្ញុំបានរៀនបានថ្នាក់ទី6ដែរនឹង

ក៖  ចឹងអ៊ុំរៀនបានថ្នាក់ទី6ដែរណាអ៊ុំ?

ខ៖  ចា៎!!នឹងហើយ

កៈ ចុះកាលពីអ៊ុំរៀននឹងអ៊ុំរៀននៅណាដែរអ៊ុំ?

ខៈ ខ្ញុំបានរៀននៅភ្នំពេញ

កៈ អូ៎!!សាលាមានឈ្មោះអីគេដែរអ៊ុំ?

ខៈ ខ្ញុំអត់ស្គាល់ខ្ញុំភ្លេចបាត់ហើយនឹង
ខ្ញុំចាស់ណាស់ហើយនឹងគ្រាន់អក្សរឥឡូវនឹងខ្ញុំភ្លេចដែរអក្សរនឹង

កៈ ប៉ុន្តែអ៊ុំបានរៀនពីបីសាលាដែរតើហីអ៊ុំមិនមែនរៀនតែមួយសាលាណាហីអ៊ុំ?

ខៈ ខ្ញុំរៀនតែមួយសាលានឹងហាស ខ្ញុំរៀនតាំងពីថ្នាក់ស្រះអ
ស្រះអាចឹងហាសណាស់រហូតដល់ ព្រៃអាតិចឹងហាសណាស់អូន

កៈ បាទអ៊ុំបាទនឹង?

ខៈ តែឥឡូវនឹងខ្ញុំបានភ្លេចអក្សរអស់ហើយនឹងហាស

កៈ ដោយសារតែអ៊ុំខានរៀនយូរហើយណាអ៊ុំ?

ខៈ ប៉ុន្តែខ្ញុំអាមើលស្គាល់ឈ្មោះខ្លួនឯងនឹង ឯកសារអីនឹងខ្ញុំអាមើលឃើញ

កៈ បាទអ៊ុំបាទ ចុះអ៊ុំគិតថាអ៊ុំមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេ?

ខៈ ខ្ញុំចេះតែខ្មែរនឹងតែម្ដងនឹង

កៈ ចុះភាសាបារាំងអីក៏អ៊ុំអត់មានចេះដែរ?

ខៈ អត់ចេះអីទាំងអស់នឹង

កៈ បាទអ៊ុំ
ចុះអ៊ុំគិតថានៅពេលដែរអ៊ុំរៀនអ៊ុំមានដែរមានមិត្តភក្តិដែរធំធាត់ដើរលេងជាមួយគ្នាដែរទេ?

ខៈ អត់អត់មានទេខ្ញុំអត់ដែរចេះមានមិត្តភក្តិដើមមកនឹងខ្ញុំអត់ចេះតែម្ដងនឹង

កៈ អូ៎!!ចឹងហោសមីង?

ខៈ តាំងពីក្មេងរហូតដល់ចាស់នឹងក៏មិនដែរចេះមានដែរខ្ញុំអត់ចេះសោះ

ក៖ អូ!!ចឹងហោសអ៊ុំ
ចុះអ៊ុំគិតថាអ៊ុំធ្លាប់បានធ្វើការងារអីគេដែរតាំងពីក្មេងរហូតមកដល់ពេលនេះហាស មានការងារអីគេខ្លះដែរទៅអ៊ុំ?

ខ៖ ការងារការងាររបស់ខ្ញុំនឹងពីក្មេងរហូតទាល់មានប្តីនឹងខ្ញុំធ្វើឆ្នប

ក៖ ធ្វើឆ្នប អូអ៊ុំធ្វើឆ្នបហោសអ៊ុំ?

ខ៖ ចា៎!!នឹងហើយធ្វើឆ្នបខ្មែរនឹង

ក៖ អូ!!ប៉ុន្តែអ៊ុំមានធ្លាប់ធ្វើស្រែអីទេអ៊ុំ?

ខ៖ ធ្វើស្រែនឹងធ្វើ

ក៖ លក្ខណះថាធ្វើស្រែចំការអីនឹងហោសអ៊ុំ?

ខ៖ ធ្វើស្រែចំការអីនឹងធ្វើ

ក៖ ចុះសំរាប់អ៊ុំធ្វើស្រែនឹងអ៊ុំធ្វើអីគេដែរទៅ?

ខ៖ ធ្វើខ្ញីគោគេចឹងទៅ

ក៖ ដក ស្ទូង ភ្ជួររាស់?

ខ៖ ដក ស្ទូងអោយគេចឹងទៅយកគោមកប្រើចឹងទៅ

ក៖ អូ!!បាទអ៊ុំបាទ ចុះអ៊ុំគិតថាអ៊ុំមានធ្លាប់បើកអាជីវកម្មលក់ដូរអីទេ?

ខ៖ អត់ទាំងអស់នឹង

ក៖ ចុះអ៊ុំគិតថាអ៊ុំធ្លាប់ចិញ្ចឹមសត្វដែរទេអ៊ុំ?

ខ៖ ចិញ្ចឹមប៉ុន្តែឥឡូវនឹងចិញ្ចឹមលែងកើតហើយនឹង

ក៖ អូ!!ចឹងហោសអ៊ុំ?

ខ៖ ពីមុននឹងចិញ្ចឹមគោ ចិញ្ចឹមជ្រូកអីនឹងប៉ុន្តែចិញ្ចឹមអីកើតទេ

ក៖ មាន់ ទាអ៊ុំធ្លាប់ចិញ្ចឹមទេ?

ខ៖ មាន់ ទា ចិញ្ចឹមទាំងអស់នឹង

ក៖ ប៉ុន្តែចិញ្ចឹមនឹងលក្ខណៈថាជាខ្នាតធំ រឺមួយក៏ខ្នាតតូចដែរអ៊ុំ?

ខ៖ ខ្នាតធម្មតានឹងខ្នាតលក្ខណៈជាគ្រួសារនឹង

ក៖ អូ៎!!ជាគ្រួសារណាអ៊ុំ?

ខ៖ ចា៎!! នឹងហើយចឹង

ក៖ ចុះអ៊ុំគិតថាជីវិតរបស់អ៊ុំនឹងមានការផ្លាស់ប្តូរតាំងពីក្មេងរហូតមកដល់ពេលនេះហាស កាលពីក្មេងនឹងយ៉ាងម៉េចដែរឥឡូវនឹងយ៉ាងម៉េចដែរចឹងហាសមានការផ្លាស់ប្តូរអីគេដែរទៅ?

ខ៖ ពីក្មេងនឹងនៅជាមួយឪពុកម្តាយនឹងវាអត់
តែដល់ពេលឥឡូវនឹងថាវានៅជាមួយកូនចៅនឹងវាគ្រាន់

ក៖ បាទអ៊ុំបាទដល់ពេលឥឡូវនឹងជីវភាពរបស់យើងនឹងអត់មានអីទេ?

ខ៖ អត់អីទេ

ក៖ ប៉ុន្តែសុខភាពរបស់យើងនឹងឥឡូវនឹងក៏មិនសូវអីដែរ?

ខ៖ ក៏អត់អីដែរ

ក៖ អូ៎!!ចុះម្ហូបអីគេដែរអ៊ុំចូលចិត្តពិសារដែរអ៊ុំ?

ខ៖
ម្ហូបឥឡូវនឹងដូចថាវាប្លែកដល់ពេលដែរយើងវាចាស់ចឹងដូចថាវាហូបមិនសូវកើតដែរនឹងហាស

ក៖ ចុះឥលូវនឹងលក្ខណៈថា?

ខ៖ សាច់ជ្រូកសាច់អីនឹងហូបមិនសូវជាកើតដែរនឹងហាស

ក៖ ចុះលក្ខណៈថាចៀន ឆា ស្ងោរ អីចឹងអ៊ុំកើតថាម្ហូបអីដែរអ៊ុំចូលចិត្តដែរទៅ?

ខ៖ ចា៎!!ខ្ញុំចូលចិត្តនឹងចូលចិត្តតែថាពិបាកនឹងចូលចិត្តណាស់ដូចថាថ្ងៃនេះចង់នេះទៅ ហើយថ្ងៃនោះចឹងចង់នោះចឹងទៅ

ក៖ អូ៎!!ចឹងអ៊ុំ?

ខ៖ ថ្ងៃណាចង់ចឹងទៅក្ដាមបុកចឹងទៅគ្រាន់បានជ្រះៗមាត់ចឹងទៅ

ក៖ អូ៎!!ចឹងហោសអ៊ុំ?
ខ៖ ជួនណាបាយជាមួយស្វាយទុំនឹងស្ករត្នោតយើងចឹងទៅ

ក៖ អូ៎!!ម៉េចចឹង?

ខ៖ ខ្ញុំហូបចឹង

ក៖ ចុះអ៊ុំគិតថាល្បែងប្រជាប្រិយ៍អីដែរអ៊ុំចូលចិត្តលេងតាំងពីក្មេងហាស?

ខ៖ តាំងពីក្មេងហោសលេងតែបោះឈូង ទំលាក់កូនកន្សែង ស្វាចាំទី ហើយនឹងលាក់សន្លឹកគេហៅដណ្ដើមស្លឹកឈើនឹងហាស

ក៖ ចុះបោះអង្គុញរឺមួយក៏?

ខ៖ បោះអង្គុនឹងខ្ញុំអត់សូវចូលចិត្តដែរនឹងពីព្រោះខ្ញុំបោះអត់ត្រូវទេ

ក៖ ចុះអ៊ុំគិតថាអ៊ុំទៅលេងនឹងអ៊ុំលេងនៅណាដែរអ៊ុំ?

ខ៖ ខ្ញុំហោសឥឡូវនឹងរឺពីមុន

ក៖ ពីមុនហាសអ៊ុំ

ខ៖ ពីមុនខ្ញុំលេងលក្ខណៈថាតាមបន្ទាយទាហ៊ានចឹងទៅ

ក៖ អូ៎!!ចឹងហោសអ៊ុំ?

ខ៖ នៅជាមួយឪពុកម្ដាយចឹងទៅខ្ញុំលេងជាមួយពយកទាហ៊ានចឹងទៅនឹង

ក៖ អូ៎!!ចុះអ៊ុំចេះរាំទេ?

ខ៖ អត់អីទេអារៀងរាំនឹងតែឥឡូវនឹង

ក៖ អទ់អីទេប៉ុន្តែអ៊ុំពូកែរាំណាអ៊ុំ?

ខ៖  អើរខ្ញុំលេខមួយហើយនឹង

ក៖  អូ៎!!ចឹងហោសអ៊ុំ?

ខ៖  ប៉ុន្តែគ្រាន់តែឥឡូវខ្ញុំឈប់លេងហើយនឹង

ក៖  ប៉ុន្តែអ៊ុំចេះច្រៀងទេអ៊ុំ?

ខ៖  អត់ទេឥឡូវនឹងហោស

ក៖  ប៉ុន្តែពីមុននឹងអ៊ុំចេះ?

ខ៖  ពីមុននឹងខ្ញុំចេះតែបើការ៉ាអូខេនឹងខ្ញុំចេះច្រៀងតាមអក្សរគេ

ក៖  ប៉ុន្តែឥឡូវនឹងអ៊ុំចេះច្រៀងតាមអក្សរណាអ៊ុំ?

ខ៖ តាមអក្សរនឹងចេះ

ក៖  ភាគច្រើននឹងអ៊ុំចូលចិត្តច្រៀងបទអីគេដែរទៅ?

ខ៖  ចេះតែច្រៀងចឹងទៅ

ក៖  ប៉ុន្តែភាគច្រើននឹងបទអីគេដែរលក្ខណះបទបុរាណ រឺមួយក៏បទបុរាណដែរអ៊ុំចូលចិត្តច្រៀងហាស?

ខ៖  អូ៎!!ចេះតែច្រៀងចឹងទៅបទបុរាណនឹងណាស់ តែសម័យឥឡូវនឹងខ្ញុំអត់ចេះទេ

ក៖  តែឥឡូវនឹងអ៊ុំដាក់មួយឃ្លាហីអ៊ុំ?

ខ៖  អត់ទេខ្ញុំអត់ចេះទេ

ក៖  បាទ!!ខ្ញុំនិយាយលេងទេអ៊ុំអត់អីទេ?

ខ៖  ឥឡូវនឹងវាសម័យពិបាកណាស់វាហាក់លោតៗៗមិនដឹងថាស្អីគេទេ

ក៖  បាទ!!អ៊ុំប៉ុន្តែអ៊ុំចូលចិត្តស្តាប់ឃីកេ អាយៃ ល្ខោនអីទេ?

ខ៖  ខ្ញុំចូលចិត្តស្តាប់ចាប៉ី

ក៖  អូ៎!!ស្តាប់ចាប៉ីដែរ នឹងតើអ៊ុំចូលចិត្តស្តាប់ធិមអីដែរតើហីអ៊ុំ?

ខ៖ នឹងហើយស្តាប់ធិមនឹងស្តាប់លោតទេសស្តាប់អីនឹងចឹង

ក៖ អូ៎!!បាទអ៊ុំបាទ មួយនឹងល្អអ៊ុំ?

ខ៖ ចា៎!!នឹងហើយល្អ?

ក៖ ចុះអ៊ុំគិតថាមាននរណាគេម្នាក់នៅក្នុងក្រុមគ្រួសារអ៊ុំចេះលេងឧបករណ៍ភ្លេងដែរទេអ៊ុំ?

ខ៖ អត់ទេ

ក៖ អត់មានទេបងប្អូនកូនក្មួយអីនឹងក៏អត់ចេះដែរ?

ខ៖ អត់ចេះទេចេះតែសំណង់ចេះតែ

ក៖ អូ៎!!ចេះសំណង់ហោសអ៊ុំ?

ខ៖ នឹងហើយចេះតែប៉ុណ្ណឹងទេ យើងភ្លេងភ្លោតអីនឹងអត់ដឹងទេ

ក៖ ធ្វើការហោសអ៊ុំ?

ខ៖ ចា៎!!ដឹងតែធ្វើការរកហូបរកចុកនឹង

ក៖
ចុះអ៊ុំគិតថាផ្ទះរបស់អ៊ុំនឹងមានលក្ខណះបែបណាតាំងពីក្មេងរហូតមកដល់ពេលនេះហាស ថាពីក្មេងនឹងផ្ទះយ៉ាងម៉េចហើយឥឡូវនឹងផ្ទះយ៉ាងម៉េចចឹងហាសអ៊ុំ?

ខ៖ ពីក្មេងតូចជាងនឹងដល់ពេលខ្លួនចាស់នឹងបានប៉ុណ្ណឹង

ក៖ ចុះពីក្មេងនឹងនរណាគេជាអ្នកសាងសងផ្ទះនឹងហាសអ៊ុំ?

ខ៖ ពីក្មេងហោស ពីក្មេងនឹងម្តាយឪពុករបស់ខ្ញុំនឹងហាស

ក៖ អូ៎!!ប៉ុន្តែដល់ពេលឥឡូវនឹង?

ខ៖ ឥឡូវនឹងមានតែខ្លួនឯងនឹង

ក៖ ប៉ុន្តែមាននរណាគេម្នាក់នៅក្នុងផ្ទះអ៊ុំចេះសាងសងផ្ទះដែរទេ?

ខ៖ កូនខ្ញុំហី កូនរបស់ខ្ញុំទាំងអស់ហី

ក៖ បាទមាននរណាគេមួយចេះសាងសងផ្ទះដែរទេ?

ខ៖ ពួកខ្ញុំនឹងអត់មាននរណាគេចេះផងនឹង

ក៖ អូ្ន!!ចឹងយើងសងផ្ទះនឹងយើងជួលគេណាអ៊ុំ?

ខ៖ ចា៎!!ជួលគេនឹងហាស

ក៖ អូ្ន!!គ្រាន់តែយើងជាអ្នកចេញលុយអីចឹងទៅ?

ខ៖ ចា៎!!ដូចថាពីមុនគេថាកុំអោយយកកាំបិតចិតដងឯង

ក៖ យើងអត់អាចសងដោយខ្លួនឯងហោសអ៊ុំ?

ខ៖ ចា៎!!នឹងហើយសុខចិត្តអស់ឈ្នួលនឹងកាំបិតមិនអាចចិតដងឯងបានទេ គ្មាននរណាអាចដកពីកាំបិត ហើយនឹងយកមកចិតទេនឹងហាស

ក៖ អូ្ន!!ចឹងទេហោសអ៊ុំ
ចុះអ៊ុំគិតថាផ្ទះរបស់អ៊ុំនឹងគេប្រើឧបករណ៍អីគេខ្លះដែរអ៊ុំសំរាប់សាងសងវាដែរ?

ខ៖ មានកាំបិតពូថៅចឹងទៅ ដែកដាប់ចឹងទៅ

ក៖ ដែកដាប់ ដែកគោល?

ខ៖ រណាចឹងទៅ ប្រដាប់វាស់ទឹកចឹងទៅ

ក៖ បាទអ៊ុំបាទ ចុះជំនាញអីដែរអ៊ុំចេះស្ទាត់ជំនាញដែរអ៊ុំ?

ខ៖ ជំនាញនឹងមានតែធ្វើស្រែនឹងហាស

ក៖ ធ្វើស្រែណាអ៊ុំ?

ខ៖ ចា៎!!មានតែធ្វើស្រែនឹងដក ស្ទូងនឹងហាសជំនាញហើយនឹងត

ក៖ ចុះលក់ដូរអីនឹងអ៊ុំគិតថាជំនាញដែរទេ?

ខ៖ អត់ទេនឹង

ក៖ ចឹងអត់ទេណាអ៊ុំ?

ខ៖ ចា៎!!នឹងហើយ

កៈ ចុះអ៊ុំគិតថាឪពុកម្ដាយរបស់អ៊ុំនឹងគាត់មានធ្លាប់បង្រៀនពីជំនាញអីទៅអ៊ុំទេ?

ខៈ គាត់អត់មានជំនាញខាងធ្វើអីផងនឹង
គាត់ដូចថាគ្មានរកអីគាត់បើគាត់នឹងអ្នកក្រីក្រនឹងដែរនឹង

កៈ បាទអ៊ុំបាទ ចុះលក្ខណៈវេញវល្លិ៍ កូរស្ករត្នោត ធ្វើឆ្កៅ ធ្វើកន្ទេលអីនឹងអត់ទេណាអ៊ុំ?

ខៈ អត់អត់មានទេ

កៈ ចឹងអត់មានទេណាអ៊ុំ?

ខៈ ធ្វើតែជាទាហ៊ានរហូតនឹងហាស

កៈ អូ៎!!បាទ
ចុះអ៊ុំអាចប្រាប់ពីជីវិតរបស់អ៊ុំតាំងពីក្មេងរហូតមកដល់ពេលនេះមានការលំបាកអីគេខ្លះដែរចឹងហាសអ៊ុំ?

ខៈ ឥឡូវនឹងពិបាកតែរហូតដែរនឹង លំបាកអត់ហូបអត់ចុកចឹងទៅ

កៈ ចុះកាលពីក្មេងអ៊ុំមានការលំបាកអីគេដែរ?

ខៈ រកលុយរៀនក៏មិនបាន

កៈ ចឹងនៅឆ្នាំ1955អ៊ុំបានកើត ចុះនៅឆ្នាំ1960ជាងនឹងអ៊ុំមានការលំបាកបាកអីទេ
ដូចជាជំនាន់យាគកុង ជំនាន់លុនណុលអ៊ុំមានការលំបាកអីគេដែរ?

ខៈ អានឹងដើរតាមឪពុកម្ដាយ

កៈ អូ៎!!អ៊ុំអត់មានធ្វើអីទេណាអ៊ុំ?

ខៈ ចា៎!!ពេលណុងអត់មានធ្វើអីទេនឹង

កៈ ប៉ុន្តែនៅក្នុងស្រុកទេសយើងនឹងមានសង្គ្រាមអីនៅអ៊ុំ?

ខៈ មានហើយនឹងសង្គ្រាមនឹង

កៈ គេហៅគ្រាប់ផ្លោងអីច្រើននឹងហោសអ៊ុំ?

ខ៖ ចា៎!!គ្រាប់ផ្លោងគ្រាប់ប៉េ ចូលត្រង់សេដៃរនឹងឡានហោះអីនឹងគេទំលាក់គ្រាប់បែកអីនឹងហាស

ក៖ អូ៎!!ប៉ុន្តែនរណាគេដៃរឈ្លោះជាមួយនរណាគេដៃរធ្វើអោយមានគ្រាប់ផ្លោងនៅខ្មែរដៃរអ៊ុំពេលណុង?

ខ៖ លុនណុលឈ្លោះជាមួយនរណាដៃរខ្ញុំមិនសូវដឹងទេ

ក៖ ឈ្លោះជាមួយវៀតណាមហីអ៊ុំ?

ខ៖ ចា៎!!កាលណុលជាមួយយាគកុងនឹង

ក៖ អូ៎!!យាគកុងនឹងវៀតណាមហោសអ៊ុំ?

ខ៖ ចា៎!!យាគកុងនឹងវៀតណាមនឹង

ក៖ ប៉ុន្តែវាមកដល់ទឹកដីខ្មែរដៃររឺមួយយ៉ាងម៉េចដៃរអ៊ុំ?

ខ៖ វាមកដល់ដៃរតើនឹង

ក៖ វាមកធ្វើអីដៃរអ៊ុំ?

ខ៖ វាមកខាងៗៗនឹងហាសវាមកចាំបាញ់ទាហ៊ានអីចឹងទៅណាស់

ក៖ អូ៎!!ប៉ុន្តែវាចូលទឹកដីខ្មែរហោសអ៊ុំ?

ខ៖ ចា៎!!

ក៖ បាទអ៊ុំ!!រហូតទាល់តែអ៊ុំ ចុះពេលណុងអ៊ុំអាយុប៉ុន្មានដៃរអ៊ុំ?

ខ៖ ខ្ញុំមិនទាន់ដឹងអាយុដៃរនឹងហាស អាយុកាលណុងវាចូលខ្ទង់ម្ភៃជាងហើយហី

ក៖ អត់ទេជំនាន់?

ខ៖ ជំនាន់លុនណុលនឹងហី

ក៖ ជំនាន់លុនណុលនឹងហាស អ៊ុំអាយុម្ភៃជាងណា បើអ៊ុំទើបនឹងកើតនៅឆ្នាំ1955នឹង?

ខ៖ នឹងហើយចឹង

កៈ បើលុនណុលនឹងឆ្នាំហុកជាងអីនឹងចឹងអ៊ុំប្រហែលជាអាយុដប់ឆ្នាំជាងអីនឹងហាស?

ខៈ នឹងហើយខ្ញុំមិនទាន់បានប្ដីផងនឹងកាលណុង

កៈ ប៉ុន្តែអ៊ុំបានប្ដីនៅឆ្នាំ?

ខៈ អ្ហូ!!ខ្ញុំមិនសូវចងចាំទេ

កៈ ប៉ុន្តែអ៊ុំបានប្ដីនឹងមុនពលពតហីអ៊ុំ?

ខៈ ចា៎!!មុននឹងពលពតចូល

កៈ អ្ហូ!!ចឹងហោសអ៊ុំ?

ខៈ លុនណុលនឹងខ្ញុំការហើយនឹង លុនណុលនឹងខ្ញុំការហើយខ្ញុំទៅនៅកំពង់សោមនឹង

កៈ បាទអ៊ុំបាទ ចុះអ៊ុំគិតថានៅក្នុងជំនាន់ពលពតនឹងអ៊ុំមានការលំបាកអីគេខ្លះដែរទៅអ៊ុំ?

ខៈ ជំនាន់ពលពតនឹងខ្ញុំពិបាក
រឿងធ្វើការងាររកស៊ីចឹងយើងធ្វើការងារអោយគេបានៗហូបនឹង

កៈ បាទអ៊ុំបាទនឹង?

ខៈ យើងលើកកាប់គាស់ដីបានបានហូបនឹង

កៈ បាទអ៊ុំបាទនឹង?

ខៈ បើមិនចឹងទេគេអាករយើងចោលនឹង គេយកយើងទៅវៃចោលនឹង

កៈ ប៉ុន្តែគិតថាពេលណុងអ៊ុំនៅណា គេជំលាសអ៊ុំទៅណាដែរទៅ?

ខៈ ខ្ញុំគេជំលាសខ្ញុំហោសជំលាសខ្ញុំនេះមកនៅភ្នំជើងក្អែកពងនេះ

កៈ បាទអ៊ុំ ចុះគិតថាពេលណុងអ៊ុំនៅជាមួយក្រុមគ្រួសារទៀតទេនឹងអ៊ុំ?

ខៈ អត់ទេខ្ញុំបែកទាំងអស់នឹងហាស
ឪពុករបស់ខ្ញុំស្លាប់នៅកំពង់សោមនឹងម្ដាយរបស់ខ្ញុំបែកនឹង ខ្ញុំនឹងនៅម្នាក់ឯង

កៈ បាទអ៊ុំបាទ?

ខ៖ ខ្ញុំនៅម្នាក់ឯងកូនរបស់ខ្ញុំមាន3នាក់នឹង ស្លាប់កូនអស់ហើយនឹង

ក៖ ប៉ុន្តែពេលណុងឪពុករបស់អ៊ុំនឹងធ្វើអីគេដែរទៅអ៊ុំ?

ខ៖ ឪពុករបស់ខ្ញុំនឹងធ្វើជាទាហ៊ាន

ក៖ ធ្វើទាហ៊ាននៅជំនាន់ពលពតនឹងហោសអ៊ុំ?

ខ៖ ធ្វើទាហ៊ានលុនណុល

ក៖ ប៉ុន្តែពលពតនឹងគាត់ធ្វើអីគេដែរអ៊ុំ?

ខ៖ ពលពតនឹងគាត់ស្លាប់មុនទៀតនឹងហាស

ក៖ អូ៎!!ចឹងហោសអ៊ុំ?

ខ៖ គាត់ស្លាប់មុននឹងចាំ!!

ក៖ ប៉ុន្តែគិតថាគេមានជំលាសអ៊ុំទៅខេត្តណា នឹងស្រុកណាផ្សេងទៀតទេអ៊ុំ?

ខ៖ អត់មានទេគេជំលាសខ្ញុំមកនឹងតែម្តងនឹង

ក៖ អូ៎!!ពេលណុងគេអោយអ៊ុំធ្វើអីគេខ្លះដែរទៅនឹង?

ខ៖ ជំលាសខ្ញុំមកនឹងគ្មានបានធ្វើអីកាប់តែគាស់កាប់តែធ្វើ
ដីកន្លែងនៅនឹងដីព្រៃខ្លាំងគេអោយកាប់គាស់
យើងនៅចឹងទៅបើយើងមិនធ្វើគេវៃចោលនឹងហាស

ក៖ អូ៎!!ចឹងហោសអ៊ុំ ចុះអ៊ុំគេអោយធ្វើអីគេអោយតែកាប់គាស់ទេណាអ៊ុំ?

ខ៖ នឹងហើយគេអោយយើងស្កាព្រៃស្កាអីចឹងទៅ

ក៖ ប៉ុន្តែគេអោយអ៊ុំនៅជាមិត្តភក្តិជាកងនារីរឺយ៉ាងម៉េចដែរអ៊ុំ?

ខ៖ ចាំ!!ខ្ញុំនៅកងចល័ត

ក៖ ចឹងអ៊ុំនៅកងចល័តណាអ៊ុំ?

ខ៖ ចាំ!!នឹងហើយ

កៈ ដោយសារតែអ៊ុំពេលណុងអ៊ុំនៅអាយុ?

ខៈ ខ្ញុំនៅអាយុទំនងជាសែសិបឆ្នាំជាងហើយហី

កៈ អូ៎!!អ៊ុំអាយុសែជាងហើយនឹងហោសអ៊ុំ?

ខៈ នឹងហើយ

កៈ ដូចជាអាយុសាមជាងតែហីអ៊ុំ?

ខៈ សាមជាងអីនឹងហី ដូចជាខ្ញុំវាភ្លេចដែរនឹង

កៈ ប៉ុន្តែប្តីរបស់អ៊ុំនឹង គេអោយទៅណាដែរពេលណុងហាស?

ខៈ ប្តីរបស់ខ្ញុំនឹងស្លាប់នៅកោះអ្នកលឿងយើងនឹងហាស

កៈ ចុះមុនពលពតនឹងរឺក៏ពេលពលពតអ៊ុំ?

ខៈ ក្នុងពលពតពេលពលពតចូលភ្នំពេញនឹង

កៈ អូ៎!!បាទអ៊ុំចុះអ៊ុំគិតថានៅពេលដែរចប់ពលពតនឹងយើងចូលខ្មែរក្រហមណាអ៊ុំ?

ខៈ នឹងចូលខ្មែរក្រហមនឹង

កៈ ប៉ុន្តែពេលណុងមានការលំបាកអីគេដែរទៅអ៊ុំ?

ខៈ ជំនាំខ្មែរក្រហមនឹងមានការលំបាកដែរនឹងកូនលំបាកសព្វ
លំបាកគ្រប់នឹងគ្មានអីប្រៀបបានទេ លំបាកហត់ជាងគេនឹងមានតែខ្មែរក្រហមនឹងហើយ

កៈ គេធ្វើអីគេខ្លះដែរធ្វើអោយយើងពិបាកដែរអ៊ុំ?

ខៈ ចុះហូបនឹងហូបបាយ10នាក់ក្នុងមួយកំប៉ុងអីនឹងវិន នឹងបបរនឹង

កៈ អូ៎!!ដាច់ជំនាន់ពលពតហើយនឹងអ៊ុំ?

ខៈ ចា៎!!ជំនាន់ពលពតនឹងបបរ ជូនណាទៅស៊ីទុំត្នោត

កៈ បាទអ៊ុំបាទនឹង?

ខៈ ចា៎!!ទុំត្នោតបបរ ដឹងតែទុំត្នោតនឹងបបរមួយកំប៉ុងស៊ីពី100នាក់ទៅ 50នាក់នឹង

កៈ អូ!!បាទអ៊ុំ ចុះអ៊ុំនៅពេលដែរដាច់ខ្មែរក្រហមហើយនឹង
ដែរឆ្នាំកៅជាងដែរស្តេចយើងចូលស្រុកវិញ ហាសពេលណុងសប្បាយដែរទេអ៊ុំ
ពេលណុងអ៊ុំមានការលំបាកអីដែរទេ?

ខៈ អត់មានការលំបាកអីទេ

កៈ អូ!!ស្រួលហើយមែនទេអ៊ុំ?

ខៈ ពេលហូបឆ្នាំងខ្លួនឯង

កៈ ប៉ុន្តែនៅពេលមុននឹងអ៊ុំត្រូវការរកលុយចិញ្ចឹមជីវិត?

ខៈ ចាំ!!នឹងហើយ

កៈ ចុះពេលណុងអ៊ុំធ្វើការងារអីគេដែរទៅ?

ខៈ ធ្វើស្រែនឹង

កៈ ធ្វើស្រែណាអ៊ុំណា?

ខៈ ចាំ!!នឹងហើយធ្វើស្រែនឹង

កៈ អូ!!ចុះពេលណាដែរអ៊ុំគិតថាជាពេលដែរសប្បាយជាងគេនៅក្នុងឆាកជីវិតដែរអ៊ុំ?

ខៈ សប្បាយបានដូចថាឯករាជ្យចឹងទៅបានសប្បាយ
សម្តេចបានរស់នឹងចឹងទៅបានសប្បាយគ្មានពិបាក គ្មាននឿយគ្មានហាត់អីនឹង

កៈ បាទអ៊ុំបាទនឹង?

ខៈ ដូចថាឆ្នាំងខ្លួនយើង ស្លៀកពាក់ខ្លួនរបស់ខ្លួនយើងនឹងហាស

កៈ បាទអ៊ុំបាទត្រូវហើយ
ចុះអ៊ុំគិតថាការលំបាករបស់អ៊ុំទាំងអស់នឹងដែរអ៊ុំបានរៀបរាប់មិញនឹង
ដូចជាអ៊ុំឆ្លងកាត់នឹងជំនះឧបសគ្គដោយរបៀបណាដែរអ៊ុំ?

ខៈ ឆ្លងកាត់វាឆ្លងកាត់លំបាកនោះលំបាករកអីនិយាយមិនបានទេ

កៈ  អូ!!បាទអ៊ុំបាទ
ចុះពេលដែរអ៊ុំការរឺមួយពេលដែរកូនចៅនៅជុំគ្នានឹងអ៊ុំគិតថាពេលណាងសប្បាយដែរទេ?

ខៈ  សប្បាយដែរនឹង

កៈ
អូ!!បាទកាលពីពេលក្មេងអ៊ុំធ្លាប់គិតថាអ៊ុំធ្លាប់មានក្ដីសង្ឃឹមថាពេលដែរធំឡើងនឹងអ៊ុំចង់ធ្វើអីទេ នៅក្នុងជីវិតរបស់អ៊ុំហាស?

ខៈ  ជីវិតរបស់ខ្ញុំហោស

កៈ  បាទអ៊ុំបាទនឹង?

ខៈ  មានចង់ធ្វើអីទេ ខ្ញុំចង់ធ្វើតែស្រែចិញ្ចឹមតែកូននឹងហាស

កៈ  អូ!!ចឹងណាអ៊ុំ ចុះអ៊ុំបើសិនជាចង់អោយអ៊ុំផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗ
តើអ៊ុំចង់ផ្ដែផ្ដាំអីទៅគាត់ដែរអ៊ុំ?

ខៈ  ខ្ញុំផ្ដែផ្ដាំទាំងអស់នឹងទាំងការងារលំបាកទាំងប៉ុន្មាននឹងខ្ញុំផ្ដែផ្ដាំទាំងអស់នឹង

កៈ  អូ!!ថាកុំអោយគាត់ធ្វើតាមហោសអ៊ុំ?

ខៈ  ចា៎!!

កៈ  បាទអ៊ុំបាទ ចុះបើសិនអ៊ុំគិតថាអោយពួកគាត់ជៀសវៀងវិញនឹង
តើអ៊ុំចង់អោយពួកគាត់ជៀសវៀងនៅអីគេខ្លះដែរទៅអ៊ុំជៀសវៀងហាស?

ខៈ  ចា៎!!ជៀសវៀងហោស

កៈ  បាទជៀសវៀងពីអំពើផឹកស៊ីនឹងអំពើ?

ខៈ  ជៀសវៀងចឹងផឹកស៊ីនឹង

កៈ  ជក់គ្រឿងញៀនអីចឹងទៅ?

ខៈ  ជៀសពីអំពើគួរស្អប់ខ្ពើមអីនឹង

កៈ  ទាំងអំពើគ្រឿងញៀនអីនឹងហោសអ៊ុំ?

ខះ  នឹងហើយចង់អោយកូនជៀសវៀងទាំងអស់នឹងហាស

កះ  អូ៎!!បាទអ៊ុំបាទ
ចុះអ៊ុំធ្លាប់គិតថាចង់អោយពួកគាត់សំរេចនៅគោលបំណង់ដែរអ៊ុំបានប៉ងពីមុនមកនឹង តើចង់អោយគាត់សំរេចដែរទេអ៊ុំ?

ខះ  នឹងមិនមើលចិត្តវាឃើញដែរនឹងហាស

កះ  អូ៎!!នឹងគាត់ធ្វើអ្វីតាមដែរគាត់ធ្វើណាអ៊ុំ?

ខះ  ចា៎!!បើខ្ញុំសំរេចចិត្តធ្វើចឹងហើយបើកូនសំរេចចិត្តថាធ្វើនឹងអានឹងតាមវា

កះ  បាទអ៊ុំបាទ ចុះអ៊ុំមានគិតថាមានអីដែរអ៊ុំចង់ផ្ដែផ្ដាំទៅគាត់ទៀតទេអ៊ុំ?

ខះ  ខ្ញុំផ្ដែផ្ដាំតែប៉ុណ្ណឹងឯង

កះ  អូ៎!!ចឹងណាអ៊ុំមានតែប៉ុណ្ណឹងណាអ៊ុំ?

ខះ  ហាមដាច់ខាតតែសង្គមគេស្អប់ខ្ពើមនឹងហើយកុំអោយជួបអោយសោះ

កះ  បទអ៊ុំបាទ
ចឹងជាចុងក្រោយប្រហែលជាខ្ញុំអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់អ៊ុំ ហើយការសំភាសន៍ទាំងអស់នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅ អាមេរិច
ហើយយើងនឹងតំកល់ទុកប្រវត្តិរបស់យើងនឹងទៅក្នុងសាលាដើម្បីសាលាអាចរក្សាទុកតំក ល់អោយ ពួកគាត់បានស្គាល់នឹងបានដឹងពីប្រវត្តិឪពុកម្ដាយនឹងដូនតាចឹងហាសអ៊ុំ
បាទអរគុណច្រើនអ៊ុំ៕៕៕